ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

មជ្ឈមណ្ឌលសកម្មភាព
កំចាត់មីនកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីពិធីចុះហត្ថលេខា
## "គម្រោងសាងសង់អគារហ្វឹកហ្វឺននៅវិទ្យាស្ថានបច្ចេកទេសសកម្មភាពកំចាត់មីន និងអគារផ្សព្វផ្សាយអប់រំយល់ដឹងពីសង្គ្រាម ( សារមន្ទីរតេជោសន្តិភាព )"
## រវាង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) និង ក្រុមហ៊ុន SATO KOGYO CO., LTD

មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) នឹងរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី "គម្រោងសាងសង់អគារហ្វឹកហ្វឺននៅវិទ្យាស្ថានបច្ចេកទេសសកម្មភាពកំចាត់មីន នៅខេត្តកំពង់ឆ្នាំង និងអគារផ្សព្វផ្សាយអប់រំយល់ដឹងពីសង្គ្រាម( សារមន្ទីរតេជោសន្តិភាព )" នៅខេត្តសៀមរាប ដែលនឹងត្រូវចុះហត្ថលេខារវាង **ឯកឧត្តម ហេង រតនា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC) និង**លោក Jun KATO** អគ្គនាយកក្រុមហ៊ុន SATO KOGYO CO., LTD ។

គម្រោងនេះនឹងជួយលើកកម្ពស់សមត្ថភាពអង្គភាពCMAC ក្នុងវិស័យសកម្មភាពមីននៅកម្ពុជា និងក្នុងការជួយពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសមានបញ្ហាគ្រាប់មីន និងសំណល់យុទ្ធភណ្ឌសង្គ្រាម ដើម្បីជម្រុញការលុបបំបាត់បញ្ហាគ្រាប់មីននិងសំណល់យុទ្ធភណ្ឌសង្គ្រាមនៃបណ្តាប្រទេសទាំងនោះ នាំមកនូវសុខសុវត្ថិភាពរបស់ប្រជាជននិងគាំទ្រការអភិវឌ្ឍន៍ប្រទេសឡើងវិញ។

អង្គភាពCMACសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ប្រជាជន និងរដ្ឋាភិបាលជប៉ុនដែលតែងតែគាំទ្រយ៉ាងសកម្មលើវិស័យសកម្មភាពមីននៅកម្ពុជា។ ជាពិសេសការផ្តល់ជំនួយជាថវិកា ទីប្រឹក្សាបច្ចេកទេស និងសម្ភារបច្ចេកទេសដល់អង្គភាពCMACក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ក្នុងការលុបបំបាត់ការគំរាមកំហែងដោយសារគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះសំណល់សង្គ្រាម ការចូលរួមផ្តល់នូវក្តីសុខដុមរមនារបស់ប្រជាជនកម្ពុជាឡើងវិញ និងការចូលរួមកសាងអនាគតកម្ពុជាប្រកបដោយក្តីសង្ឃឹមនិងភាពជឿជាក់នៅកម្ពុជា ក៏ដូចជាកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានាលើវិស័យកំចាត់មីននេះ។

ពិធីចុះហត្ថលេខានេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង១៤:៣០នាទីរសៀល នៅទីបញ្ជាការដ្ឋានស៊ីម៉ាក់ភ្នំពេញ ដែលមានអាសយដ្ឋាន អាគារស៊ីម៉ាក់ ស្ថិតនៅផ្លូវឌួងងៀប ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤

**<u>លេខទូរសព្ទទំនាក់ទំនង៖</u>**
**ឯកឧត្តម ផាត ភារៈ**
លេខទូរសព្ទៈ ០៨៨ ៩៩៩៣៤៥៦